# ជំពូក ៦

# ការប្រឹក្សា និង ពិគ្រោះយោបល់ ពីសាធារណជន

## Public Consultation

Draft

# ជំពូកទី ៦

# ការប្រឹក្សា និង ពិគ្រោះយោបល់ ពីសាធារណជននៅក្នុងតំបន់គំរោង

## ៦.១ សេចក្តីផ្តើម

ការប្រឹក្សា និងពិគ្រោះយោបល់ពីសាធារណជនដែលពាក់ព័ន្ធដោយសារគំរោងនេះ គឺជាចំណុចមួយដ៏សំខាន់ដែលធ្វើឡើងដើម្បីឱ្យសាធារណជនដែលពាក់ព័ន្ធទាំងនេះផ្តល់នូវមតិយោបល់ និងសំណូមពរក្នុងការជួយដល់ការអនុវត្តន៍គំរោងឱ្យបានល្អប្រសើរ និងមានភាពរលូន ។

ការប្រឹក្សា និងពិគ្រោះយោបល់នេះ ធ្វើឡើងនូវដំណាក់កាលរចនាគំរោង ដែលធ្វើឱ្យសាធារណជនពាក់ព័ន្ធទាំងនោះបានដឹងឮថា មានក្រុមហ៊ុន នឹងមកវិនិយោគលើគំរោងវិនិយោគសំរាប់វារីអគ្គិសនីកំចាយ ខេត្តកំពតក្នុងតំបន់របស់គាត់ ។

រយៈពេលការធ្វើការប្រឹក្សា និងពិគ្រោះយោបល់ពីសាធារណជន ដែលពាក់ព័ន្ធដោយសារគំរោងនេះគឺ ១៤ថ្ងៃ (០៣ ដល់ ១៦/០៩/២០០៦) ។

ការប្រឹក្សា និងពិគ្រោះយោបល់នេះ បានធ្វើការពិភាក្សាវែកញែក និងពន្យល់ដល់ស្ថាប័នរដ្ឋ អង្គការមិនមែនរដ្ឋាភិបាល និងប្រជាពលរដ្ឋនៅក្នុងតំបន់គំរោងបានយល់ អំពីគោលបំណងនៃការអភិវឌ្ឍន៍គំរោង ដែលទៅថ្ងៃអនាគតនឹងនាំឱ្យពួកគាត់បានរីកចំរើន (ចូលរួមចំណែកជាមួយរាជរដ្ឋាភិបាល ក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋក្នុងតំបន់គំរោង) ។

Draft

## ៦.២ គោលបំណងនៃការប្រឹក្សា

គោលបំណងនៃការប្រឹក្សា និងពិគ្រោះយោបល់ពីសាធារណជន មានគោលបំណងដូចតទៅ :

- ធ្វើការផ្សព្វផ្សាយដល់សាធារណជន និងអ្នកដែលពាក់ព័ន្ធនឹងគំរោងទាំងអស់ បានដឹងឮអំពីគោលបំណង និងដំណាក់កាលនៃការអនុវត្តន៍គំរោងនេះ ។
- ស្វែងរកមតិរិះគន់ សំណូមពរ បញ្ហាទំនាស់ និងរកវិធីសាស្ត្រកែលំអរផ្សេងៗរបស់ពួកគេទាំងនោះ ។
- ធ្វើការដោះស្រាយទំនាស់ទាំងនោះដោយធ្វើការប្រជុំពិភាក្សាជាមួយគាត់និងមានការចូលរួមអំពីសំណាក់អាជ្ញាធរមូលដ្ឋានដែលពាក់ព័ន្ធក្នុងតំបន់គំរោង ។

## ៦.៣ កំណត់ហេតុនៃការប្រឹក្សា និងពិគ្រោះយោបល់ពីសាធារណជន

ក្រុមការងារសិក្សាស្រាវជ្រាវផ្នែកការវាយតំលៃហេតុប៉ះពាល់បរិស្ថានសង្គមដំបូងរបស់ SAWAC បានធ្វើការប្រឹក្សា និង ពិគ្រោះយោបល់ពីសំណាក់សាធារណជនដែលពាក់ព័ន្ធមានដូចតទៅ :

- តំណាងអ្នកគ្រប់គ្រងឧទ្យានជាតិបូកគោ
- តំណាងមន្ទីរបរិស្ថាន ខេត្តកំពត
- តំណាងមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល
- តំណាងអង្គភាពរដ្ឋាករទឹក ខេត្តកំពត
- តំណាងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ខេត្តកំពត
- តំណាងខ័ណ្ឌរដ្ឋបាលព្រៃឈើ ខេត្តកំពត

- តំណាងមន្ទីរធនធានទឹក និង ឧតុនិយម ខេត្តកំពត
- តំណាងមន្ទីរទេសចរណ៍ ខេត្តកំពត
- អភិបាលរង ស្រុកកំពង់បាយ ខេត្តកំពត
- អភិបាលរង ស្រុកកំពត ខេត្តកំពត
- សន្ទុបទីមួយ ឃុំម៉ាកប្រាង
- តំណាងមណ្ឌលសុខភាពកំពង់ត្រែង
- ប្រជាពលរដ្ឋដែលរស់នៅក្នុងភូមិមាត់ពាម ភូមិអណ្តូងជីម៉ឺន ភូមិម៉ាក់ប្រាំង ភូមិកំពង់ក្រុង ភូមិកំពង់ត្រែង ភូមិព្រៃត្នោត ភូមិស្ពំប្រាំពីរ និងអ្នកលក់ដូរនៅរមណីយដ្ឋានទឹកឈូ
- អង្គការមិនមែនរដ្ឋាភិបាល Coastal Zone Management (CZM) និងអង្គការ Cambodia Global Action (CGA).

### ៦.៣.១ កំណត់ហេតុនៃការប្រជុំពិភាក្សា និងប្រឹក្សាយោបល់របស់ក្រុមការងារជាមួយអភិបាលរងស្រុកកំពង់បាយ

ការប្រជុំពិភាក្សា និងប្រឹក្សាយោបល់ជាមួយ លោក **ស៊ុំ ឆាយ** អភិបាលរងស្រុកកំពង់បាយ ធ្វើឡើងថ្ងៃទី ០៤/០៩/២០០៦ វេលាម៉ោង ២:៤៥ ដល់ ៣:៤០ មានដូចតទៅ :

- លោកបានមានប្រសាសន៍ថា សព្វថ្ងៃខេត្តកំពតមានចរន្តអគ្គិសនីប្រើប្រាស់តែនៅទីរួមខេត្ត និងទីរួមស្រុកប៉ុណ្ណោះ ហើយមានតំលៃខ្ពស់ទៀតផង ( ១២០០ រៀល ក្នុង ១គីឡូវ៉ាត់ ) ។ ដោយឡែកនៅស្រុកកំពង់បាយដែលជាស្រុកទីរួមខេត្ត មានសកម្មភាពសិប្បកម្មធន់តូច និងមធ្យមមួយចំនួនធំដែលពឹងផ្អែកលើថាមពលអគ្គិសនីសំរាប់ដំណើរការ ។ ដូច្នេះស្រុកក៏ដូចជាប្រជាជនដែរត្រូវការចាំបាច់នូវចរន្តអគ្គិសនីគ្រប់គ្រាន់ដើម្បីបំរើការងារអភិវឌ្ឍន៍នៅក្នុងតំបន់នេះ ។
- លោកក៏សង្ឃឹមទុកថា តំលៃអគ្គិសនីនឹងចុះថោកនៅពេលដែលវារីអគ្គិសនីនេះសាងសង់រួច ។
- លោកបានផ្តល់ពត៌មានទៀតថា ព្រែកកំពង់បាយដែលជាផ្នែកចុងក្រោយនៃព្រែកទឹកឈូ មានរស់ជាតិប្រៃ ដោយសារការសាយចូលនៃទឹកសមុទ្រ ។ ការជន់លិចនៅលើទឹកដីស្រុកទាំងមូល តែងតែកើតមានឡើងជារៀងរាល់ឆ្នាំ ដោយសាររបបទឹកស្ទឹងកំចាយ និង ស្ទឹងកែវ។ មានត្រីឆ្លាត់ (ត្រីតាពត) ហៅត្រីនាគ រស់នៅក្នុងស្ទឹងទឹកឈូ និងស្ទឹងកែវ ។
- លោកមានចំណាប់អារម្មណ៍ថា អាជ្ញាធរស្រុកធ្លាប់ចូលរួមវាយតំលៃលើគំរោងវារីអគ្គិសនីកំចាយ និង បណ្តាញភ្លើងដែលតមកក្រុងកំពតសំរាប់ប្រើប្រាស់ ហើយលោកគិតថានឹងមានផលប៉ះពាល់មិនធ្ងន់ធ្ងរទេដល់ព្រៃឈើ និងអនុផលព្រៃឈើក្នុងតំបន់អាងធំ ដែលត្រូវលិចលង់ខូចអស់ ។
- លោកបានផ្តល់គំនិតបន្ថែមថា បើមានការអភិវឌ្ឍន៍គំរោងវារីអគ្គិសនីកំចាយ នោះនឹងមានផលប្រយោជន៍ ច្រើនដល់ប្រជាជនក្នុងតំបន់ និងប្រទេសជាតិ គឺមានថាមពលអគ្គិសនីប្រើប្រាស់ រួមចំណែកអភិវឌ្ឍន៍ វិស័យ

Draft

ឧស្សាហកម្ម ទេសចរណ៍ និងកសិកម្ម ឈានទៅរកភាពរីកចំរើន ដែលអាចកាត់បន្ថយភាពក្រីក្រក្នុងតំបន់ និង ទូទាំងប្រទេសកម្ពុជា ។

- លោកអបអរសាទរនឹងគំរោងនេះ ហើយមិនជំទាស់នឹងការអភិវឌ្ឍន៍នេះទេ ។

### ៦.៣.២ កំណត់ហេតុនៃការប្រជុំពិភាក្សា និងប្រឹក្សាយោបល់ខាងក្រុមការងារ ជាមួយតំណាង មន្ទីរកសិកម្ម ខេត្តកំពត

ការប្រជុំពិភាក្សា និងប្រឹក្សាយោបល់ជាមួយ លោក **ចាន់ ចេស្តា** ប្រធានមន្ទីរកសិកម្មខេត្តកំពត ធ្វើឡើងថ្ងៃទី ០៤/០៩/២០០៦ វេលាម៉ោង ៤:00 ដល់ ៥:00 ល្ងាច មានដូចតទៅ :

- លោកបានដឹងអំពីគំរោងវារីអគ្គិសនីកំចាយ គឺតាមរយៈការប្រជុំគណៈកម្មាការអភិវឌ្ឍន៍ខេត្ត នៅដើមឆ្នាំ ២០០៦ នេះ ។
- ទាក់ទងនឹងប្រភេទមច្ឆាជាតិក្នុងតំបន់គំរោង លោកប្រធានមន្ទីរបានបញ្ជាក់ថា ពុំមានការសិក្សាអំពីប្រភេទត្រី ហើយនឹងមានទិន្នន័យច្បាស់លាស់អំពីត្រីស្ថិតនៅក្នុងស្ទឹងកំចាយ និងស្ទឹងកែវនៅឡើយរហូតដល់សព្វថ្ងៃនេះ ។
- លោកសំដែងការស្វាគមន៍ចំពោះគំរោងវារីអគ្គិសនីកំចាយ ហើយចំណាប់អារម្មណ៍ថា នឹងមានផលប្រយោជន៍ច្រើនដល់ប្រជាជនក្នុងតំបន់ និងប្រទេសជាតិ គឺមានថាមពលអគ្គិសនីប្រើប្រាស់ រួមចំណែកអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ទេសចរណ៍ និងកសិកម្មទៀតផង ។ តែលោកបារម្ភថា គំរោងអាចធ្វើឱ្យរបបទឹកនៅផ្នែកខាងក្រោមនៃទំនប់ខ្វះខាតនារដូវប្រាំង នោះនឹងមានផលប៉ះពាល់ដល់ការស្រោចស្រព ក្នុងវិស័យកសិកម្មរបស់ប្រជាជនក្នុងមូលដ្ឋានដែលរស់នៅខ្សែទឹកខាងក្រោម ។
- លោកប្រធានបានរាយការណ៍ជូនក្រុមសិក្សានូវផ្ទៃដីដាំដុះរបស់ស្រុកពីរដែលជាប់ទាក់ទងនឹងតំបន់គំរោង គឺ ស្រុកកំពង់បាយ និង ស្រុកកំពត ។ ស្រុកកំពង់បាយមានផ្ទៃដីស្រែជាក់ស្តែង ១៥១០០ហ.ត ក្នុងនេះធ្វើស្រែប្រាំង ២០០ហ.ត និងធ្វើស្រែវស្សា ១៥១០០ហ.ត ដីដំណាំរួមផ្សំមាន ២៩៥ ហ.ត និងដីដំណាំឧស្សាហកម្ម (សណ្តែកដី អំពៅ ល្ង) មាន ៧៧ហ.ត ។ ស្រុកកំពតមានផ្ទៃដីស្រែជាក់ស្តែង ៥៧៥ហ.ត ហើយជាស្រែវស្សាទាំងអស់ ដីដំណាំរួមផ្សំមាន ២១ ហ.ត និងដីដំណាំឧស្សាហកម្មមានតែ ២ហ.ត ប៉ុណ្ណោះ ។

### ៦.៣.៣ កំណត់ហេតុនៃការប្រជុំពិភាក្សា និងប្រឹក្សាយោបល់ខាងក្រុមការងារជាមួយតំណាងអង្គការ គំរោងគ្រប់គ្រងតំបន់ឆ្នេរសមុទ្រខេត្តកំពត Coastal Zone Management "CZM"/DANIDA

ការប្រជុំពិភាក្សា និងប្រឹក្សាយោបល់ជាមួយ លោក **ទើន ទិរៈ** នាយកគំរោងគ្រប់គ្រងតំបន់ឆ្នេរសមុទ្រ ខេត្តកំពត CZM បានធ្វើឡើង ថ្ងៃទី ០៤/០៩/២០០៦ វេលាម៉ោង ៥:00 ដល់ ៦:00 ល្ងាចមានដូចតទៅ :

- លោកនាយកគំរោងគ្រប់គ្រងតំបន់ឆ្នេរសមុទ្រ ខេត្តកំពត បានលើកឡើងនូវសក្តានុពលធនធានសត្វ និងរុក្ខជាតិសមុទ្រក្នុងតំបន់សមុទ្រ ខេត្តកំពត ក្រោមការសិក្សារបស់គំរោងលោក និងការសិក្សាពីមុនមក រួមមានត្រីសមុទ្រជាង ៤០០ ប្រភេទ រួមទាំងផ្សោតសមុទ្រ ។ ស្មៅសមុទ្រមានដុះយ៉ាងច្រើននៅតំបន់សមុទ្រ ខេត្តកំពត ផ្កាថ្មក៏មានវត្តមាននៅទីនេះផងដែរ ។

Draft

- លោកបានរាយការណ៍ថា មានប្រភេទត្រីមួយចំនួនរស់នៅ និងបង្កកំនើតក្នុងតំបន់ទឹកភ្លៀវនៃស្ទឹងកំពង់បាយ ដូចជាត្រីស្លង់ក្រហម និងត្រីស្លង់ស ។ ពុំមានការសិក្សាណាមួយបញ្ជាក់ច្បាស់លាស់ពីប្រភេទត្រីរស់នៅក្នុងតំបន់ស្ទឹងកំចាយ ព្រែកកំពង់បាយ និងស្ទឹងកែវនេះឡើយ ។ ប៉ុន្តែតាមពត៌មានពីប្រជាជនរស់នៅក្នុងតំបន់នេះតែងនេសាទបាន ត្រីស្លង់ក្រហម ត្រីស្លង់ស និង ត្រីមួយចំនួនទៀត នៅក្នុងព្រែកកំពង់បាយ ត្រីតាពត (ហៅត្រីនាគ) និងកន្ធាយនៅផ្នែកខាងលើនៃស្ទឹងកំចាយ និងមានប្រភេទក្រពើអាស៊ី ហៅថា Siam Crocodize រស់នៅតំបន់នេះទៀតផង ។
- ប្រភេទជីវសាស្ត្រដែលការពាររួមមាន ផ្សោតសមុទ្រ ជ្រូកទឹក ស្មៅសមុទ្រ និង ផ្កាថ្ម ។
- យោងតាមការស្រាវជ្រាវរបស់ CZM បង្ហាញថាបរិមាណមច្ឆាសមុទ្រ និងត្រីទឹកភ្លៀវថយចុះ ឬបាត់បង់ បើមានការបំផ្លាញដើមស្មាច់ (Lumisira) ហើយនាំឱ្យប៉ះពាល់ដល់ដើមកោងកាង Mangrove ដែលជាគ្រោះថ្នាក់ដល់ប្រព័ន្ធអេកូឡូស៊ីតំបន់ឆ្នេរសមុទ្រទាំងមូល ។
- លោកក៏មានការព្រួយបារម្ភចំពោះគំរោងវារីអគ្គិសនីកំចាយនេះ អាចបង្កនូវការបំពុលគុណភាពទឹក និងការរំខានដល់បំលាស់ទីរបស់ត្រីមួយចំនួន ។ ប៉ុន្តែគំរោងវារីអគ្គិសនីនេះនឹងផ្តល់ផលប្រយោជន៍យ៉ាងប្រសើរ ចំពោះតំរូវការថាមពលសំរាប់ការអភិវឌ្ឍន៍ប្រទេសជាតិលើគ្រប់វិស័យ និង កាត់បន្ថយការប្រើប្រាស់ធនធានព្រៃឈើហួសប្រមាណសំរាប់ការចំអិនអាហាររបស់ប្រជាជនក្នុងតំបន់ និងទូទាំងប្រទេស ។
- លោកបានសំដែងការស្វាគមន៍ និងចង់ឱ្យគំរោងវារីអគ្គិសនីនេះសាងសង់ឆាប់ៗ តាមតែអាចធ្វើទៅបាន ។ និងសំណូមពរដល់ម្ចាស់គំរោង និងក្រុមសិក្សាវាយតំលៃផលប៉ះពាល់បរិស្ថានធ្វើយ៉ាងណារកដំណោះស្រាយ កាត់បន្ថយរាល់ផលប៉ះពាល់អវិជ្ជមាន ដល់ធនធានបរិស្ថាន និងធនធានសង្គមឱ្យដល់កំរិតអប្បបរមា ។

Draft

### ៦.៣.៤ កំណត់ហេតុនៃការប្រជុំពិភាក្សា និងប្រឹក្សាយោបល់ជាមួយតំណាង មន្ទីរធនធានទឹក និងឧតុនិយម ខេត្តកំពត

ការប្រជុំពិភាក្សា និងប្រឹក្សាយោបល់ជាមួយ លោក **ចាន់ វណ្ណា** ប្រធានមន្ទីរធនធានទឹក និង លោក **ឃី នាង** អនុប្រធានមន្ទីរធនធានទឹក បានធ្វើឡើងថ្ងៃទី ០៥/០៩/២០០៦ វេលាម៉ោង ៨:០០ ដល់ ៩:០២ ព្រឹក មានដូចតទៅ :

- លោកបានរាយការណ៍ជូនក្រុមការងារថា នៅរដូវប្រាំងអូសបន្លាយនៅចុង ឆ្នាំ ២០០៤ និងនៅឆ្នាំ ២០០៥ ទឹកប្រៃនៃព្រែកកំពង់បាយឡើងដល់កន្លែងបូមទឹក (ក្បែររមណីយដ្ឋានទឹកឈូ) របស់អង្គភាពរដ្ឋាករទឹកខេត្តកំពត ។
- ទឹកជំនន់តែងតែកើតមានជារៀងរាល់ចុងឆ្នាំ សំរាប់តំបន់កំចាយនេះ ជាក់ស្តែងនៅថ្ងៃទី ១៣ ដល់ថ្ងៃទី ១៥ ខែសីហា ឆ្នាំ ២០០៦ នេះមានព្យុះភ្លៀងយ៉ាងខ្លាំងនៅក្នុងខេត្តនេះ ហើយរយៈពេល ២ ថ្ងៃជាប់ៗគ្នាបន្ទាប់ពីភ្លៀងធ្លាក់ ទឹកភ្លៀងនេះបានប្រមូលតាមផ្ទៃរងទឹកភ្លៀងរបស់ព្រែកទឹកឈូ និងស្ទឹងកែវ ហូរមកជន់លិចខេត្តកំពតចាប់ពីថ្ងៃទី ១៥ ដល់ ២០ ខែ សីហា ឆ្នាំ ២០០៦ ។
- លោកប្រធានមន្ទីរបានសួរថា ក្នុងករណីមានភ្លៀងធ្លាក់ខ្លាំង ដូច ឆ្នាំ២០០៦ នេះ តើគំរោងទំនប់វារីអគ្គិសនីកំចាយនេះអាចទប់ជំនន់បានរយៈពេលប៉ុន្មានម៉ោង រឺប៉ុន្មានថ្ងៃ ? កន្លងមកតំបន់កំចាយនេះមានជំនន់ខ្លាំងៗ ជាច្រើនលើកមកហើយ ដូចជានៅឆ្នាំ ១៩៩៩ ឆ្នាំ ២០០០ និង ឆ្នាំ២០០៦ នេះ ។

- លោកប្រធានមន្ទីរបានផ្តល់ទិន្នន័យមួយចំនួនដូចជា កំពស់ទឹកភ្លៀង ហើយមន្ទីរពុំមានទិន្នន័យអំពីធារទឹក និង កំពស់ទឹកជំនន់ទេ ព្រោះគ្មានឧបករណ៍សំរាប់វាស់ ។
- សព្វថ្ងៃមន្ទីរពុំមានផែនការយកទឹកប្រើប្រាស់ នៅខ្សែទឹកខាងក្រោមនៃទឹកឈូនោះទេ ។
- លោកប្រធានមន្ទីរធនធានទឹក ឧតុនិយម និងជលសាស្ត្រ បានសំដែងការស្វាគមន៍ចំពោះគំរោងវារីអគ្គិសនីកំចាយ ហើយយល់ថា គំរោងនេះនឹងផ្តល់ផលប្រយោជន៍យ៉ាងច្រើន ចំពោះតំរូវការថាមពលសំរាប់ការអភិវឌ្ឍន៍ប្រទេសជាតិលើគ្រប់វិស័យ ។
- លោកបានសំណូមពរដល់ក្រុមហ៊ុនឱ្យទុកកន្លែងបម្រុងសំរាប់យកទឹកនៅអាងទី២សំរាប់ស្រោចស្រពដល់ដីកសិកម្មក្នុងតំបន់ទៅថ្ងៃអនាគត ។

### ៦.៣.៥ តំណត់ហេតុនៃការប្រជុំពិភាក្សា និងប្រឹក្សាយោបល់ខាងក្រុមការងារ ជាមួយតំណាងអ្នកគ្រប់គ្រងឧទ្យានជាតិបូកគោ

ការប្រជុំពិភាក្សា និងប្រឹក្សាយោបល់ជាមួយ លោក **យិន មុនី** អនុប្រធានឧទ្យានជាតិបូកគោ បានធ្វើឡើងថ្ងៃទី ០៥/០៩/២០០៦ វេលាម៉ោង ៩:១៥ ដល់ ១០:៣០ ព្រឹក មានដូចតទៅ :

- លោកអនុប្រធានបានបង្ហាញជូននូវផ្ទៃដីសរុបរបស់ឧទ្យានជាតិគឺ ១៤៩.៨៩៥ ហ.ត លាតសន្ធឹងលើដីរដ្ឋបាលខេត្តចំនួនបួនរួមមាន ខេត្តកំពត ក្រុងព្រះសីហនុ ខេត្តកោះកុង និងខេត្តកំពង់ស្ពឺ ។ តំបន់សត្វព្រៃឆ្លងកាត់ មានទំហំដីប្រមាណ ៨.១៨៣ ហ.ត ហើយសព្វថ្ងៃនេះ (ថ្ងៃទី ០៥/០៩/២០០៦) មានអង្គការពីរគឺ WildAid ជួយឧបត្ថម្ភលើការងារតាមដាន សិក្សាអង្កេត និងថែរក្សាអភិរក្សសត្វព្រៃក្នុងឧទ្យានជាតិ និង WSC ជួយពង្រឹងសមត្ថភាព និងផ្សព្វផ្សាយដល់សហគមន៍ដែលនៅជុំវិញតំបន់បូកគោ ។
- លោកបានរាយការណ៍ថា នៅឆ្នាំ ១៩៩៨-៩៩ នាយកដ្ឋានការពារអភិរក្សធម្មជាតិរបស់ក្រសួងបរិស្ថាន បានសិក្សាពីរុក្ខជាតិនៅក្នុងតំបន់ឧទ្យានជាតិបូកគោ ហើយរបាយការណ៍នៃការសិក្សានោះមាននៅក្រសួងបរិស្ថាន ។
- យោងតាមការសិក្សារបស់អង្គភាពលោក បានបង្ហាញថា មានប្រជាពលករប្រមាណជាង ២០០នាក់ ដែលមានរបរប្រចាំថ្ងៃពឹងផ្អែកលើអនុផលព្រៃឈើក្នុងតំបន់គំរោងវារីអគ្គិសនីនេះ ។ ពួកគេចូលទៅកាប់ឫស្សី បោចផ្តៅ កាប់អូស ។
- មន្ត្រីនៃអង្គភាពឧទ្យានជាតិបូកគោទាំងអស់បានធ្វើការយ៉ាងសកម្មក្នុងការការពារ និង ទប់ស្កាត់បទល្មើសកាប់ព្រៃ ដាក់អន្ទាក់ចាប់សត្វនៅក្នុងឧទ្យានជាតិ ជាក់ស្តែងអង្គភាពបាននាំខ្លួនជនល្មើសមកអប់រំ រឹបអូស ឧបករណ៍មធ្យោបាយ និងវត្ថុតាង រួមមានម៉ាស៊ីនរណាអារឈើជាង ៤០០គ្រឿង កង់រាប់សិបគ្រឿង និងឈើមានតំលៃ (ឈើខ្មៅ) រាប់រយកំណាត់ទៀតផង ។ ប៉ុន្តែបទល្មើសលើឧទ្យានជាតិបូកគោនៅមាននៅឡើយ តែមានតិចតួច ។ សព្វថ្ងៃមានអ្នកកាន់កាប់ដីធ្វើចំការក្នុងឧទ្យានជាតិត្រង់តំបន់ទឹកឈូនេះ ។
- អង្គភាពឧទ្យានជាតិបូកគោ បានដឹងពិតមានអំពីគំរោងវារីអគ្គិសនីកំចាយនៅត្រឹម ឆ្នាំ ២០០២ ដោយបានចូលរួមប្រជុំជាមួយមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តកំពត និងក្រុមសិក្សារបស់ប្រទេសកាណាដា ។ ក្រោយពីឆ្នាំនោះមកពុំដែលបានទទួលពតិមានអំពីគំរោងវារីអគ្គិសនីកំចាយនេះទេ ។ ទើបថ្ងៃដែលក្រុមការងារសិក្សាហេតុ

ប៉ះពាល់បរិស្ថាន និងសង្គមដំបូងនេះបានជូនពត៌មាន និងពន្យល់ពីគោលបំណងនៃការអភិវឌ្ឍន៍វារីអគ្គិសនីកំចាយ ខេត្តកំពត ដែលវិនិយោគដោយក្រុមហ៊ុនចិន SINIHYDRO ។

- លោកអនុប្រធានឧទ្យានជាតិពុំជំទាស់ចំពោះគំរោងវារីអគ្គិសនីកំចាយ ដែលអភិវឌ្ឍន៍ដោយក្រុមហ៊ុនចិននេះទេ ប៉ុន្តែចង់ឱ្យមានការចូលរួមពីស្ថាប័នពាក់ព័ន្ធទាំងអស់ ក្នុងការអនុវត្តន៍ហេដ្ឋារចនាសម្ព័ន្ធនានា ក្នុងឧទ្យានជាតិ ដើម្បីឱ្យមាននិរន្តភាព និងមានការដោះស្រាយសមស្រប ។ ព្រោះគំរោងអាចបង្កឱ្យមានផលប៉ះពាល់ ដូចជាការលិចលង់ព្រៃឈើនិងអនុផលព្រៃឈើ ការបាត់បង់ជំរកសត្វ និងការប្រែប្រួលបរិស្ថានក្នុងឧទ្យានជាតិនេះ ។
- លោកសំណូមពរឱ្យមានការសិក្សាចំពោះផលប៉ះពាល់ និងរកវិធានការកាត់បន្ថយផលប៉ះពាល់អាក្រក់ទាំងនោះ ។ បន្ថែមពីលើនេះទៀតសូមឱ្យរាជរដ្ឋាភិបាល និងក្រុមហ៊ុនជួយផ្តល់ជាបច្ចេកទេស និងថវិកា សំរាប់ដាំដុះព្រៃឈើ ឬស្សី ផ្តៅ នៅទីតាំងក្បែរនោះជំនួសការបាត់បង់ដោយសារគំរោង ។

### ៦.៣.៦ កំណត់ហេតុនៃការប្រជុំពិភាក្សានិងប្រឹក្សាយោបល់របស់ក្រុមការងារ ជាមួយតំណាងខ័ណ្ឌរដ្ឋបាលព្រៃឈើ ខេត្តកំពត

ការប្រជុំពិភាក្សា និងប្រឹក្សាយោបល់ជាមួយ លោក **ពត ផាន់ណា** អនុខ័ណ្ឌរដ្ឋបាលព្រៃឈើ និង លោក **ខេង ឈង** នាយសង្កាត់រដ្ឋបាលព្រៃឈើ ឃុំកំពង់បាយ និងឃុំបឹងទូក បានធ្វើឡើងថ្ងៃទី ០៥/០៩/២០០៦ វេលាម៉ោង ១០:៤៥ ដល់ ១១:៣០ ព្រឹក មានដូចតទៅ :

- តំបន់គំរោងវារីអគ្គិសនីកំចាយភាគច្រើនស្ថិតនៅក្នុងឧទ្យានជាតិបូកគោ ដែលគ្រប់គ្រងដោយក្រសួងបរិស្ថាន និងអង្គភាពឧទ្យានជាតិបូកគោផ្ទាល់តែម្តង ដូចនេះពុំជាទាក់ទងខ្លាំងជាមួយអង្គភាពខ័ណ្ឌរដ្ឋបាលព្រៃឈើ ។ ប៉ុន្តែកន្លងទៅថ្មីៗនេះ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល បានធ្វើលិខិតស្នើសុំកាប់សំអាតឈើ (ទំហំ ២០០០ម x ៥០០ម) នៅកន្លែងសាងសង់ទំនប់ ទី១ និងកន្លែងសាងសង់ឃ្លាំង ផ្ទះស្នាក់នៅរបស់កម្មករ ។
- លោកបានផ្តល់ពត៌មានទៀតថា មុនឆ្នាំ ១៩៩៧ ក្នុងតំបន់ផ្ទៃដីដែលត្រូវលិចក្នុងតំបន់គំរោងនេះ មានការកាប់ព្រៃឈើយ៉ាងអនាធិបតេយ្យ ។ ក្រោយពីមានអង្គភាពអភិរក្សថែរក្សាឧទ្យានជាតិបានចូលមកការពារ យាមកាម ដើរល្បាត ធ្វើឱ្យតំបន់នេះត្រូវបានអភិរក្ស និងការពារឡើងវិញ ។
- លោកទាំងពីរដែលតំណាងឱ្យអង្គភាពខ័ណ្ឌរដ្ឋបាលព្រៃឈើយល់ស្របទាំងស្រុងចំពោះគំរោងនេះ ។

### ៦.៣.៧ កំណត់ហេតុនៃការប្រជុំពិភាក្សា និងប្រឹក្សាយោបល់របស់ក្រុមការងារជាមួយអភិបាលរងស្រុកកំពត

ការប្រជុំពិភាក្សា និងប្រឹក្សាយោបល់ជាមួយលោក **សៅ សំបូរ** អភិបាលរងស្រុកកំពត និង លោក **ស្វ ផន** នាយខុទ្ទកាល័យស្រុក ធ្វើឡើងថ្ងៃទី ០៥/០៩/២០០៦ វេលាម៉ោង ៣:៣០ ដល់ ៤:៣០ ល្ងាច មានដូចតទៅ :

- លោកអភិបាលរងស្រុកកំពត បានរាយការណ៍ថា លោកបានដឹងឮគំរោងនេះតាំងពីដើមឆ្នាំ ២០០៦ ម្លេះតាមរយៈការចូលរួមប្រជុំជាមួយមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តកំពត ។ ប៉ុន្តែលោកបានជ្រាបរឹតតែច្បាស់នៅពេលដែលក្រុមការងារសិក្សាអំពីហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូងនេះ ។
- លោកក៏បានផ្តល់ទិន្នន័យមួយចំនួនដល់ក្រុមការងារ និងបានធ្វើការផ្តល់ប្រឹក្សាដល់ក្រុមនេះផងដែរ ។

Draft

- លោកស្វាគមន៍ក្នុងការអភិវឌ្ឍវារីអគ្គិសនីក្នុងតំបន់របស់គាត់ ពីព្រោះស្រុកកំពតនេះត្រូវការនូវថាមពលអគ្គិសនី ដើម្បីអភិវឌ្ឍន៍ស្រុករបស់ខ្លួន ហើយលោកសង្ឃឹមថាតំលៃអគ្គិសនីនឹងចុះថោកនៅពេលដែលវារីអគ្គិសនីនេះសាងសង់រួច ។
- លោកបានសំណូមពរសូមឱ្យ រាជរដ្ឋាភិបាលដោះស្រាយប្រជាពលរដ្ឋ ដែលមានដីប៉ះពាល់ដោយសារគំរោង និង ប្រជាពលរដ្ឋដែលប៉ះពាល់ដល់មុខរបររបស់គាត់ ដូចជាអ្នកលក់ដូរនៅទឹកឈូជាដើម ។ល។

## ៦.៣.៨ កំណត់ហេតុនៃការប្រជុំពិភាក្សា និងប្រឹក្សាយោបល់ខាងក្រុមការងារ ជាមួយមេភូមិមាត់ពាម និងប្រជាជនភូមិមាត់ពាម

ការប្រជុំពិភាក្សា និងប្រឹក្សាយោបល់ជាមួយ លោក **ស៊ាង តេក** មេភូមិមាត់ពាម និងប្រជាជនភូមិមាត់ពាមចំនួន ២១នាក់ បានធ្វើឡើងថ្ងៃទី ០៦/០៩/២០០៦ វេលាម៉ោង ៣:៣០ ដល់ ៥:០០ ល្ងាច មានដូចតទៅ :

- លោកមេភូមិ និងប្រជាជនបានដឹងគំរោងនេះនៅពេលដែលឃុំបើកអង្គប្រជុំឆ្នាំ ២០០៥ ក៏ប៉ុន្តែ លោកបានជ្រាបច្បាស់អំពីគោលបំណង និងទិសដៅនៃការអភិវឌ្ឍន៍វារីអគ្គិសនីនេះពេលដែលក្រុមការងារសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្ខេបដំបូងនេះ បានពន្យល់ប្រាប់ ។
- លោកក៏បានរាយការណ៍អំពីអ្នកភូមិរបស់លោកចូលទៅក្នុងព្រៃក្នុងតំបន់គំរោង ដើម្បីកាប់ឫស្សី និងរកអុសមានចំនួនប្រមាណ ៣០នាក់ ក្នុងម្នាក់ៗអាចរកចំណូលបានចាប់ពី ១០០០០ ទៅ ១៥០០០រៀលក្នុងមួយថ្ងៃ ។
- លោកអបអរសាទរជាមួយគំរោងនេះ ដោយសារគំរោងនេះអាចបន្ធូរបន្ថយទឹកជំនន់ ដែលជារឿងរាល់ឆ្នាំ តែងតែជន់លិចពី ៦០ ទៅ ៧០% នៃផ្ទៃដីភូមិសរុប ជាក់ស្តែងថ្ងៃទី ១៥ ដល់ ២០ ខែ សីហា កន្លងទៅនេះ ទឹកជំនន់លិចផ្ទៃដីភូមិប្រមាណ ៩៨% ដែលធ្វើឱ្យខូចស្រូវ និងផលដំណាំផ្សេងៗទៀតជាច្រើន ។
- ក្នុងពេលប្រឹក្សាយោបល់នេះ មានប្រជាជន ៣ នាក់បដិសេធមិនគាំទ្រគំរោងនេះ ដោយសារគាត់មានការភ័យខ្លាចបាក់ទំនប់ និងបាក់ភ្នំ ព្រោះអ្នកភូមិបានឃើញទឹកផុសចេញពីជើងភ្នំ ដែលស្ថិតនៅក្នុងតំបន់គំរោងនេះ ។
- ប្រជាជន និងលោកមេភូមិមានសំណូមពរដល់ក្រុមហ៊ុន និងរាជរដ្ឋាភិបាលធ្វើយ៉ាងណា សិក្សាឱ្យបានច្បាស់លាស់នូវប្រភេទដីក្នុងតំបន់គំរោង ជៀសវាងការបាក់ទំនប់ និងរំកិលភ្នំ ។ បន្ថែមពីលើនេះទៀត ប្រជាពលរដ្ឋដែលប៉ះពាល់សំណូមពរដល់រាជរដ្ឋាភិបាល ឱ្យទុកដីដែលនៅសល់ពីការធ្វើហេដ្ឋារចនាសម្ព័ន្ធវារីអគ្គិសនីឱ្យពួកគាត់ អាចបន្តការដាំដុះប្រមូលយកផលលើដំណាំទាំងនោះ ជាពិសេសសូមរាជរដ្ឋាភិបាលមេត្តាជួយដល់ប្រជាពលរដ្ឋដែលប៉ះពាល់នោះផង ព្រោះពួកគាត់គ្មានដីសំរាប់បង្កបង្កើនផលទៀតទេ ។

បញ្ជីវត្តមានអ្នកភូមិមាត់ពាមដែលបានចូលរួមប្រជុំពិគ្រោះយោបល់មានភ្ជាប់នៅឧបសម្ព័ន្ធ៤ ។

## ៦.៣.៩ កំណត់ហេតុនៃការប្រជុំពិភាក្សា និងប្រឹក្សាយោបល់ខាងក្រុមការងារ ជាមួយតំណាងអង្គភាពរដ្ឋាករទឹក ខេត្តកំពត

ការប្រជុំពិភាក្សា និងប្រឹក្សាយោបល់ជាមួយ លោក **ទង់ សាមុន** នាយករងអង្គភាពរដ្ឋាករទឹក ខេត្តកំពត បានធ្វើឡើងថ្ងៃទី ០៧/០៩/២០០៦ វេលាម៉ោង ៨:០០ ដល់ ៩:១៥ ព្រឹក មានដូចតទៅ :

Draft

- លោកបានដឹងថាមានគំរោងធ្វើវារីអគ្គិសនីនេះ តាមរយៈក្រុមហ៊ុនដែលចុះមកខួងដីសិក្សា ក៏ប៉ុន្តែ លោកទើបតែជ្រាបច្បាស់នូវកម្មវត្ថុគោលបំណងនៃការអភិវឌ្ឍន៍វារីអគ្គិសនីនេះ ពេលដែលក្រុមការងារសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូងនេះបានពន្យលប្រាប់ ។
- លោកក៏បានរាយការណ៍ផងដែរថា រដ្ឋាករទឹកបានបូមទឹកពីព្រែកទឹកឈូ (កន្លែងយកទឹកស្ថិតនៅក្បែរតំបន់ទេសចរណ៍ទឹកឈូចំងាយប្រមាណ ៨ គ.ម ពីអង្គភាពរបស់លោក) ធារទឹកដែលបូមក្នុងមួយថ្ងៃ មានចំនួន ២៤០ម៣/ម៉ោង ដែលបូមដោយម៉ូទ័របូមទឹកប្រើចរន្តអគ្គិសនី ២គ្រឿង និងមានបំរុង ១គ្រឿង (សរុប ៣ គ្រឿង) ។ ទឹកនេះនាំតាមបំពង់មេយកទៅសំអាតនៅអង្គភាពរដ្ឋាករទឹក ខេត្តកំពត ដែលធ្វើការស្តារឡើងវិញដោយគំរោង Provincial Towns Improvement Project ដែលជាថវិការដ្ឋ ឥណទានពីធនាគារអភិវឌ្ឍន៍អាស៊ីុយ៍ (ADB) របស់ក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល ។ ពេលដែលគំរោងនេះចប់ ការផ្គត់ផ្គង់ទឹកស្អាតដល់ទីរួមខេត្តកំពតទាំងមូលបានត្រឹមតែ ៣០% ប៉ុណ្ណោះនៃគ្រួសារដែលរស់នៅក្នុងទីរួមខេត្តនេះ ។
- លោកក៏បានផ្តល់ប្រឹក្សាផងដែរដល់ក្រុមការងារសិក្សាហេតុប៉ះពាល់បរិស្ថាននេះថា ពេលដែលក្រុមហ៊ុនធ្វើការសិក្សាខួងដីនៅបាតស្ទឹង មានការប៉ះពាល់ដល់គុណភាពទឹក (ធ្វើឱ្យល្អក់ទឹក) ហើយប្រជាពលរដ្ឋដែលប្រើប្រាស់ទឹកនេះមានការត្អូញត្អែអំពីគុណភាពទឹករបស់អង្គភាព ដោយសារតែក្រុមហ៊ុនមិនបានផ្តល់ដំណឹងជូនរដ្ឋាករទឹកដើម្បីឱ្យរដ្ឋាករទឹកចាត់វិធានការដាក់សាច់ជូរ កំបោរបន្ថែមលើបរិមាណដែលធ្លាប់ប្រើ ។
- លោកមានការព្រួយបារម្ភផងដែរអំពីបញ្ហាគុណភាពទឹក ពីព្រោះនៅរដូវប្រាំងទឹកប្រៃឡើងចូលមកជិតដល់កន្លែងយកទឹករបស់អង្គភាពរដ្ឋាករទឹក ។ ប្រសិនបើវារីអគ្គិសនីបោះទឹកតិចបំផុតនារដូវប្រាំង (២ម៣/វិនាទី) នោះនឹងធ្វើឱ្យប៉ះពាល់ដល់គុណភាពទឹកនេះ គឺទឹកប្រៃអាចចូលមកដល់ក្បាលបូមរបស់រដ្ឋាករទឹក ។
- តំណាងអង្គភាពរដ្ឋាករទឹកសំណូមពរដល់រាជរដ្ឋាភិបាល និងក្រុមហ៊ុនដូចតទៅ :
    - ពេលដែលក្រុមហ៊ុនធ្វើការសិក្សា ឬសាងសង់អ្វីដែលប៉ះពាល់ដល់គុណភាពទឹករបស់ព្រែកទឹកឈូ សូមមេត្តាជូនដំណឹងទៅអង្គភាពរដ្ឋាករទឹកឱ្យបានមុនមួយថ្ងៃ ។
    - នារដូវប្រាំងសូមឱ្យក្រុមហ៊ុនបោះទឹកមកក្រោមយ៉ាងតិចបំផុតឱ្យបាន ៥ម៣/វិនាទី ។
    - សូមទុកកន្លែងយកទឹកចូល (Intake Water for the Town Water Supply) នៅអាងទី ២ ព្រោះអនាគតអង្គភាពនឹងធ្វើការពង្រីកនូវសមត្ថភាពផ្គត់ផ្គង់ទឹកស្អាតដល់ទីរួមខេត្ត និងស្រុកដែលរណបទីរួមខេត្តកំពតនេះ ។ ម្យ៉ាងទៀត ជៀសវាងការបូមទឹកភ្លាវទៅចែកចាយទៅអតិថិជន ។
    - ក្នុងការដឹកជញ្ជូនសម្ភារៈសាងសង់ ឬពង្រីកផ្លូវចូលទៅការដ្ឋានសាងសង់វារីអគ្គិសនីនេះ អាចធ្វើឱ្យប៉ះពាល់ដល់ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធផ្លូវ ជាពិសេសធ្វើឱ្យខូចខាតដល់ប្រព័ន្ធទុយោផ្គត់ផ្គង់ទឹកស្អាតដែលនៅសងខាងផ្លូវ សូមឱ្យរដ្ឋាភិបាល និងក្រុមហ៊ុនមេត្តាសហការណ៏ និងជួយដោះស្រាយគ្នា បើពុំនោះសោតទេ អតិថិជននៅទីរួមខេត្តកំពតច្បាស់ជាមានការខ្វះខាតទឹកស្អាតជាខ្លាំង ព្រោះនៅរដូវប្រាំងទីរួមខេត្តកំពតទាំងមូលពឹងផ្អែកលើប្រព័ន្ធទឹកស្អាតនេះ ។

Draft

- លោកអបអរសាទរជាមួយគំរោងនេះ ដោយសារគំរោងនេះធ្វើឱ្យមានថាមពលអគ្គិសនីគ្រប់គ្រាន់ ហើយតំលៃថោកក្នុងការប្រតិបត្តិប្រព័ន្ធទឹកស្អាតនៅខេត្តកំពតនេះ ។

### ៦.៣.១០ កំណត់ហេតុនៃការប្រជុំពិភាក្សា និងប្រឹក្សាយោបល់របស់ក្រុមការងារ ជាមួយតំណាងមន្ទីរទេសចរណ៍ ខេត្តកំពត

ការប្រជុំពិភាក្សា និងប្រឹក្សាយោបល់ជាមួយ លោក **សយ ស៊ីណុល** អនុប្រធានមន្ទីរទេសចរណ៍ ខេត្តកំពត បានធ្វើឡើងថ្ងៃទី ០៨/០៩/២០០៦ វេលាម៉ោង ១១:០០ ដល់ ១២:០០ ព្រឹក មានដូចតទៅ :

- លោកអនុប្រធានបានរាយការណ៍ជូនក្រុមការងារថា នៅខេត្តកំពតទាំងមូលមានរមណីយដ្ឋានទេសចរណ៍ធម្មជាតិ ៩ កន្លែង និងសួនសត្វមួយកន្លែង ។ ដោយឡែកនៅក្នុងតំបន់គំរោងវារីអគ្គិសនី មានតំបន់ទេសចរណ៍ ៣ កន្លែង គឺតំបន់សួនសត្វ និងរមណីយដ្ឋានធម្មជាតិកោះតាដា (របស់ឯកឧត្តម **ញឹម វណ្ណដា**) និងតំបន់ទេសចរណ៍ធម្មជាតិទឹកឈូ (របស់រដ្ឋ) ។ នៅរមណីយដ្ឋានទេសចរណ៍ទឹកឈូនេះ មានភ្ញៀវជាតិ និងអន្តរជាតិនិយមមកកំសាន្ត ហើយពួកគេបានចំណាយក្នុងការទេសចរណ៍នេះ ចំពោះភ្ញៀវជាតិជាមធ្យមប្រមាណ ១០ដុល្លាក្នុងម្នាក់ ហើយភ្ញៀវអន្តរជាតិបានចំណាយជាមធ្យមប្រមាណ ៤៥ដុល្លាក្នុងម្នាក់ (ចំណាយសរុបដូចជា ការស្នាក់នៅ ទិញសំបុត្រចូលទស្សនា ម្ហូបអាហារ...។ល។) ។ .
- លោកបានដឹងឮថា គំរោងអភិវឌ្ឍន៍វារីអគ្គិសនីនេះយូរមកហើយ តាមរយៈប្រជាពលរដ្ឋ និងមន្ត្រីរាជការគ្នា។ ក៏ប៉ុន្តែ លោកទើបតែបានជ្រាបច្បាស់ពីគោលបំណងក្នុងការអភិវឌ្ឍន៍វារីអគ្គិសនីនេះ ដែលវិនិយោគដោយក្រុមហ៊ុន SINOHYDRO មកពីប្រទេសចិនតាមរយៈក្រុមការងារ SAWACប៉ុណ្ណោះ (នៅថ្ងៃទី ០៨/០៩/២០០៦) ។
- លោកមានចំណាប់អារម្មណ៍ថា គំរោងនេះពុំមានការប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរដល់វិស័យទេសចរណ៍ទេ គ្រាន់តែអាចប៉ះពាល់ដល់តំបន់ទេសចរណ៍ធម្មជាតិទឹកឈូ នៅពេលការសាងសង់គំរោងនេះ ដូចជា ការប្រើប្រាស់ផ្លូវធ្វើឱ្យវិខាតដល់ភ្ញៀវទេសចរណ៍ ការទប់ទំនប់ធ្វើឱ្យខូចដល់គុណភាពទឹក (ទឹកល្អក់) ..។ល ។ ក៏ប៉ុន្តែ គំរោងនេះនាំមកនូវផលប៉ះពាល់វិជ្ជមានជាច្រើនដូចជា បានថាមពលវារីអគ្គិសនីសំរាប់ដំណើរការអភិវឌ្ឍន៍ប្រទេសជាតិ ជាពិសេសបានអាងទឹក ២ ដែលទៅថ្ងៃអនាគតអាចជាសក្តានុពលទេសចរណ៍ធម្មជាតិដ៏ល្អរបស់ខេត្តកំពត ។
- លោកបានរាយការណ៍ផងដែរថា ក្នុងតំបន់រមណីយដ្ឋានទេសចរណ៍ធម្មជាតិទឹកឈូនេះ មានតូបលក់ដូរដោយប្រជាពលរដ្ឋក្នុងតំបន់ចំនួន ៣៤ ហើយតំលៃតូបក្នុងមួយឆ្នាំគឺ ១០ម៉ឺនរៀល ។ ម្យ៉ាងទៀត អ្នកទេសចរណ៍ដែលទៅកំសាន្តនៅតំបន់នេះនាថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ ត្រូវទិញសំបុត្រគឺ រថយន្តតូចតំលៃ ២៥០០រៀល រថយន្តមីនីប៊ីសតំលៃ ៣០០០រៀល រថយន្តប៊ីសតំលៃ ៥០០០រៀល ។
- លោកបានសំណូមពរដល់រាជរដ្ឋាភិបាល និងក្រុមហ៊ុនសិក្សារកផ្លូវវាងតំបន់ទេសចរណ៍ទឹកឈូនេះ ដើម្បីរក្សាភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិ ជាពិសេសរកប្រភពចំណូលជូនរដ្ឋ និងប្រជាពលរដ្ឋក្នុងតំបន់គំរោងនេះ ។

### ៦.៣.១១ កំណត់ហេតុនៃការប្រជុំពិភាក្សា និងប្រឹក្សាយោបល់របស់ក្រុមការងារ ជាមួយភូមិព្រៃត្នោត ឃុំកំពង់ក្រែង ស្រុកកំពត

ការប្រជុំពិភាក្សា និងប្រឹក្សាយោបល់ជាមួយ លោក **ម៉ម លីដា** មេភូមិព្រៃត្នោត, លោក **ជួប ជឿន** ក្រុមប្រឹក្សាអភិវឌ្ឍន៍ឃុំ និងប្រជាពលរដ្ឋចំនួន ៣៥នាក់ ខេត្តកំពត បានធ្វើឡើងថ្ងៃទី ១៤/០៩/២០០៦ វេលាម៉ោង ០២:០០ ដល់ ០៣:៣០ ល្ងាច មានដូចតទៅ :

- លោកមេភូមិ និងប្រជាពលរដ្ឋបានដឹងពូគំរោងនេះជាយូរមកហើយ (ឆ្នាំ ២០០០) គឺឮតៗគ្នា ។ ទើបនៅថ្ងៃទី ១៤/០៩/២០០៦ នេះបានដឹងច្បាស់ពីគោលបំណង និងទំហំការអភិវឌ្ឍន៍គំរោង តាមរយៈក្រុមសិក្សាហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូងនេះ ។
- ប្រជាពលរដ្ឋ និងមេភូមិមានការព្រួយបារម្ភដូចតទៅ :
    - ខ្លាចបាក់ទំនប់ធ្វើឱ្យខូចខាតទ្រព្យសម្បត្តិប្រជាពលរដ្ឋ ស្លាប់មនុស្ស និងខូចហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ។
    - បាក់ភ្នំ ឬរអិលភ្នំចុះមកក្រោម ធ្វើឱ្យខូចខាតទ្រព្យសម្បត្តិប្រជាពលរដ្ឋ ស្លាប់មនុស្ស និងខូចហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ។
    - លិចបាត់ផ្ទៃដី (ដីដែលត្រូវលិចទឹក) បាត់បង់ព្រៃឈើ អនុផលព្រៃឈើ និងថ្នាំសង្កូវ (ថ្នាំបុរាណ) ដែលពួកគាត់ធ្លាប់ទៅប្រមូល ។
    - បាត់បង់មុខរបររបស់ប្រជាពលរដ្ឋដែលពឹងផ្អែកទៅលើអនុផលព្រៃឈើដូចជា កាប់ឫស្សី បេះផ្តៅ រកអុស ។ល ។
    - កត្តាខាងលើនេះប្រជាពលរដ្ឋមានការបារម្ភ និងភ័យខ្លាចទៅដល់កូនចៅជំនាន់ក្រោយរបស់ពួកគាត់ទៀតផង ។
    - ប្រជាពលរដ្ឋមានការព្រួយបារម្ភផងដែរ អំពីការបាត់បង់មុខរបរលក់នំបញ្ចុក រំងាស់ស្ករត្នោត ពីព្រោះពួកគាត់ត្រូវការអុសដើម្បីយកមកចំអិន និងរំងាស់ ។
    - ពួកគាត់បារម្ភខ្លាចខូះរបបទឹកសាបនៅក្នុងព្រែកទឹកឈូ នៅខ្សែទឹកខាងក្រោម ដែលបណ្តាលឱ្យទឹកប្រៃឡើងពីព្រែកកំពង់បាយ ចូលកាន់តែជ្រៅទៅខាងលើខ្សែទឹក ធ្វើឱ្យប៉ះពាល់ដល់ប្រភពទឹកប្រើប្រាស់របស់អ្នកភូមិតំបន់នេះ និងប៉ះពាល់ដល់ផលដំណាំ ព្រោះទឹកប្រៃជ្រាបចូលតាមទឹកក្រោមដីបំផ្លាញផលដំណាំ ។
    - ពួកគាត់បារម្ភពីការស្ទុយទឹកចេញពីវារីអគ្គិសនី ។
- ទោះជាយ៉ាងនេះក៏ដោយ ក៏ប្រជាពលរដ្ឋក្នុងភូមិបានរាយការណ៍ថា ពេលដែលពួកគាត់បាត់ដីព្រៃឈើក្នុងតំបន់ដែលត្រូវលិចនេះ ក៏ពួកគាត់អាចចូលព្រៃរកអនុផលព្រៃឈើនៅតំបន់ផ្សេងទៀតនៃឧទ្យានជាតិបូកគោ ព្រោះការលិចព្រៃនេះមានចំនួនតិចប៉ុណ្ណោះ បើប្រៀបធៀបទៅនឹងតំបន់ព្រៃឈើក្នុងឧទ្យានជាតិទាំងមូល ។
- ប្រជាពលរដ្ឋក៏បានត្អូញត្អែផងដែរអំពីទឹកជំនន់ ជារៀងរាល់ឆ្នាំពួកគាត់ជួបប្រទះការលំបាកដោយសារទឹកជំនន់ជន់លិចភូមិ ខូចខាតផលដំណាំ និងសត្វពាហនៈ បក្សីចិញ្ចឹម ។ល ។ ប្រសិនបើមានការបាក់ទំនប់ ឬរំកិលបាក់ភ្នំ ធ្វើឱ្យមានគ្រោះថ្នាក់ធំជាងគ្រោះទឹកជំនន់នេះជាច្រើនដង ។
- មេភូមិ និងប្រជាពលរដ្ឋក្នុងភូមិព្រៃត្នោត មានសំណូមពរសុំឱ្យរាជរដ្ឋាភិបាល និងក្រុមហ៊ុនធ្វើយ៉ាងណាសិក្សាឱ្យច្បាស់លាស់រួចសាងសង់ទំនប់ឱ្យមាំ ដោយមានការជឿទុកចិត្តបាន កុំឱ្យបាក់ទំនប់ រំកិលបាក់ភ្នំ ។ ធ្វើយ៉ាងណាសុំឱ្យបើកទឹកឱ្យគ្រប់គ្រាន់នៅរដូវប្រាំងកុំឱ្យទឹកប្រៃឡើងចូលទៅជ្រៅ ។

បញ្ជីវត្តមានអ្នកភូមិព្រៃត្នោតដែលបានចូលរួមប្រជុំពិគ្រោះយោបល់មានភ្ជាប់នៅឧបសម្ព័ន្ធ៤ ។

Draft

### ៦.៣.១២ កំណត់ហេតុនៃការប្រជុំពិភាក្សា និងប្រឹក្សាយោបល់ខាងក្រុមការងារ ជាមួយភូមិម៉ាក់ប្រាង ឃុំកំពង់ក្រែង ស្រុកកំពត

ការប្រជុំពិភាក្សា និងប្រឹក្សាយោបល់ជាមួយ លោក **ភូច សារឿន** មេភូមិម៉ាក់ប្រាង និងលោក **មិត្ត សាមឺន** ក្រុមប្រឹក្សា អភិវឌ្ឍន៍ឃុំ និងប្រជាពលរដ្ឋចំនួន ២៧នាក់ ខេត្តកំពត បានធ្វើឡើងថ្ងៃទី ១៩/០៩/២០០៦ វេលាម៉ោង ០៨:៣០ ដល់ ០៩:៥០ ព្រឹក មានដូចតទៅ :

- លោកមេភូមិ និងប្រជាពលរដ្ឋបានដឹងពួត៌រោងនេះជាយូរមកហើយ (ឆ្នាំ ២០០០) តឺពួត១គ្នា ។ ទើបនៅថ្ងៃទី ១៩/០៩/២០០៦ នេះបានដឹងច្បាស់ពីគោលបំណង និងទំហំការអភិវឌ្ឍន៍គំរោង តាមរយៈក្រុមសិក្សាហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូងនេះ ។
- លោកមេភូមិ និងប្រជាពលរដ្ឋបាននិទានរឿងពិតនៅក្នុងឆ្នាំ ១៩៤៨ មានស្តេចមុនីវង្ស បានសាងសង់ដំណាក់លើកូនភ្នំក្បែរព្រែកទឹកឈូ ។ មុនពេលស្តេចអង្គនេះចេញទៅកំសាន្តនៅតំបន់បូកគោ ព្រះអង្គបានកោះហៅហោរ៉ាឱ្យមកទស្សន៍ទាយអំពីដំណើរកំសាន្តនេះ ។ ពេលនោះលោកហោរ៉ាបានទស្សន៍ទាយថា រដូវនេះជារដូវប្រាំងអាចមានភ្លៀងធ្លាក់ធំ ហើយអាចនឹងបង្កគ្រោះថ្នាក់ដល់ព្រះអង្គ សូមព្រះអង្គកុំយាងទៅអី ។ ក៏ប៉ុន្តែ ទ្រង់ជំនះ រួចយាងទៅកំសាន្តនៅទីនោះនៅរដូវប្រាំង ។ ពេលព្រះអង្គយាងទៅដល់ ស្រាប់តែមានភ្លៀងធ្លាក់យ៉ាងធំដូចហោរ៉ាទាយមែន ។ ព្យុះភ្លៀងនេះធ្វើឱ្យរលំដើមឈើធំៗ កាត់ព្រែកទឹកឈូ ហើយទឹកហូរចាល់ដោយសារស្ទះដើមឈើទាំងនោះ ក្នុងយប់នោះទឹកបានកើនកំពស់យ៉ាងខ្លាំង ហើយធ្វើឱ្យដីនៅជើងភ្នំជ្រាយ ហើយដំណាក់ដែលសាងសង់លើកំពូលកូនភ្នំនោះរំកិលបាក់ធ្លាក់ចុះមកក្រោម ធ្វើឱ្យស្តេចអង្គនេះរសាត់តាមទឹកហើយមកទើត្រង់ម្តុំតំបន់ទឹកឈូ ពេលនោះលោក **ឈី យុគឡាយ** បានស្រង់ទ្រង់ពីក្នុងទឹកមក ។ ព្រះបាទមុនីវង្សបានប្រទានរង្វាន់ដោយផ្តល់ដីឱ្យលោកសំរាប់ដាំដំណាំ កន្លែងដីសព្វថ្ងៃនេះគឺ សួនសត្វនៅទឹកឈូរបស់ឯកឧត្តម **ញឹម វណ្ណដា** ។
- ហេតុដូចនេះហើយប្រជាពលរដ្ឋ និងមេភូមិមានការព្រួយបារម្ភដូចតទៅ :
  - ខ្លាចបាក់ទំនប់ធ្វើឱ្យខូចខាតទ្រព្យសម្បត្តិប្រជាពលរដ្ឋ ស្លាប់មនុស្ស និងខូចហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ។ បើមានការបាក់ទំនប់ប្រជាជនភូមិម៉ាក់ប្រាងនឹងមានការរងគ្រោះធ្ងន់ធ្ងរជាងគេ ។
  - បាក់ភ្នំ ឬរអិលភ្នំចុះមកក្រោម ធ្វើឱ្យខូចខាតទ្រព្យសម្បត្តិប្រជាពលរដ្ឋ ស្លាប់មនុស្ស និងខូចហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ។
  - បាត់បង់មុខរបររបស់ប្រជាពលរដ្ឋដែលពឹងផ្អែកទៅលើអនុផលព្រៃឈើ ដូចជា កាប់ឬស្សី បោចផ្តៅ រកអុស ។ល។
  - កត្តាខាងលើនេះ ប្រជាពលរដ្ឋមានការបារម្ភ និងភ័យខ្លាចទៅដល់កូនចៅជំនាន់ក្រោយរបស់ពួកគាត់ទៀតផង ។

- ប្រជាពលរដ្ឋក៏បានត្អូញត្អែរផងដែរអំពីទឹកជំនន់ ជារៀងរាល់ឆ្នាំពួកគាត់ជួបប្រទះការលំបាកដោយសារទឹកជំនន់ជន់លិចភូមិ ខូចខាតផលដំណាំ និងសត្វពាហនៈ បក្សីចិញ្ចឹម ។ល។ ប្រសិនបើមានការបាក់ទំនប់ ឬរំកិលបាក់ភ្នំ ធ្វើឱ្យមានគ្រោះថ្នាក់ធំជាងគ្រោះទឹកជំនន់នេះជាច្រើនដង ។
- មេភូមិ និងប្រជាពលរដ្ឋក្នុងភូមិម៉ាក់ប្រាង មានសំណូមពរដល់រាជរដ្ឋាភិបាល និងក្រុមហ៊ុនដូចតទៅ :
  - សូមធ្វើយ៉ាងណាសិក្សាឱ្យបានច្បាស់លាស់រួចសាងសង់ទំនប់ឱ្យមាំ ដោយមានការជឿទុកចិត្តបាន កុំឱ្យបាក់ទំនប់ រំកិលបាក់ភ្នំ ។
  - ធ្វើយ៉ាងណាសូមឱ្យបើកទឹកឱ្យគ្រប់គ្រាន់នៅរដូវប្រាំងកុំឱ្យទឹកប្រៃឡើងចូលទៅជ្រៅ ។
  - បំពាក់ឧបករណ៍ និងទូក កាណូតសំរាប់ជួយសង្គ្រោះប្រជាពលរដ្ឋ នៅពេលមានឧប្បដិហេតុកើតឡើងជាយថាហេតុ ។
  - សូមធ្វើការទូទាត់សងនៅពេលដែលគំរោងនេះធ្វើឱ្យគ្រោះថ្នាក់ និងខូចខាតដល់ប្រជាពលរដ្ឋក្នុងតំបន់
  - សូមឱ្យបង្កលក្ខណៈងាយស្រួលក្នុងការចូលបំរើការងារជាកម្មករគំរោង ពីព្រោះពួកគាត់បាត់មុខរបរចាស់ (កាប់ឫស្សី បោចវល្លិ៍ រកអុស ។ល។) ។
- លោកមេភូមិ និងប្រជាពលរដ្ឋមិនជំទាស់នឹងរាជរដ្ឋាភិបាលដែលបានចុះហត្ថលេខាជាមួយក្រុមហ៊ុនវិនិយោគលើវិស័យអគ្គិសនីនេះទេ ពីព្រោះ អ្នកភូមិទាំងអស់គ្នាមានគំរោងអភិវឌ្ឍន៍ភូមិរបស់ខ្លួនលើអាទិភាព ៣ ធំៗ ដូចជា ផ្លូវថ្នល់ ទឹកស្អាត និងអគ្គិសនីនេះឯង ។

បញ្ជីវត្តមានអ្នកភូមិម៉ាក់ប្រាង្គដែលបានចូលរួមប្រជុំពិគ្រោះយោបល់មានភ្ជាប់នៅឧបសម្ព័ន្ធ៤ ។

### ៦.៣.១៣ កំណត់ហេតុនៃការប្រជុំពិភាក្សា និងប្រឹក្សាយោបល់ជាមួយក្រុមការងារ ជាមួយភូមិកំពង់គ្រែង ឃុំកំពង់គ្រែង ស្រុកកំពត

ការប្រជុំពិភាក្សា និងប្រឹក្សាយោបល់ជាមួយ លោក **អ៊ូច ខនន** មេភូមិកំពង់គ្រែង និងប្រជាពលរដ្ឋចំនួន ២៧នាក់ ខេត្តកំពត បានធ្វើឡើងថ្ងៃទី ១៥/០៩/២០០៦ វេលាម៉ោង ០២:៣០ ដល់ ០៣:៥០ ល្ងាច មានដូចតទៅ :

- លោកមេភូមិ និងប្រជាពលរដ្ឋបានដឹងឮគំរោងនេះជាយូរមកហើយ (ឆ្នាំ ២០០០) តៗគ្នា ។ ទើបនៅថ្ងៃទី ១៥/០៩/២០០៦ នេះបានដឹងច្បាស់ពីគោលបំណង និងទំហំការអភិវឌ្ឍន៍គំរោង តាមរយៈក្រុមសិក្សាហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូងនេះ ។
- ប្រជាពលរដ្ឋបាននិទានរឿងពិត (ដូចនៅភូមិម៉ាក់ប្រាងដែរ) គឺនៅក្នុងឆ្នាំ ១៩៤៨ មានស្តេចមួយអង្គព្រះនាម មុនីវង្ស បានសាងសង់ដំណាក់លើក្នុងភ្នំក្បែរព្រែកទឹកឈូ ។ មុនពេលស្តេចអង្គនេះចេញទៅកំសាន្តនៅតំបន់បូកគោព្រះអង្គបានកោះហៅហោរ៉ាឱ្យមកទស្សន៍ទាយអំពីដំណើរកំសាន្តនេះ ។ ពេលនោះលោកហោរ៉ាបានទស្សន៍ទាយថា រដូវនេះជារដូវប្រាំងអាចមានភ្លៀងធ្លាក់ធំ ហើយអាចនឹងបង្កគ្រោះថ្នាក់ដល់ព្រះអង្គ សូមព្រះអង្គកុំយាងទៅអី ។ ក៏ប៉ុន្តែ ទ្រង់ជំនះរួចយាងទៅកំសាន្តនៅទីនោះនៅរដូវប្រាំង ។ ពេលព្រះអង្គយាងទៅដល់ស្រាប់តែមានភ្លៀងធ្លាក់យ៉ាងធំ ដូចហោរ៉ា

ទាយមែន ។ ព្យុះភ្លៀងនេះធ្វើឱ្យរលំដើមឈើធំៗ កាត់ព្រែកទឹកឈូ ហើយទឹកហូរចាល់ដោយសារស្ទះដើមឈើទាំងនោះ ក្នុងយប់នោះទឹកបានកើនកំពស់យ៉ាងខ្លាំង ហើយធ្វើឱ្យដីនៅជើងភ្នំជ្រោយ ហើយដំណាក់ដែលសាងសង់លើកំពូលកូនភ្នំនោះរំកិលបាក់ធ្លាក់ចុះមកក្រោម ធ្វើឱ្យស្ដេចអង្គនេះរសាត់ តាមទឹកហើយមកទើត្រង់ម្ដុំតំបន់ទឹកឈូ ពេលនោះលោក **លី យុគន្ធរាយ** បានស្រង់ទ្រង់ពីក្នុងទឹកមក ។ ព្រះបាទមុនីវង្សបានប្រទានរង្វាន់ ដោយផ្ដល់ដីឱ្យលោកសំរាប់ដាំដំណាំកន្លែងដីសព្វថ្ងៃនេះគឺ សួនសត្វនៅទឹកឈូ របស់ឯកឧត្ដម **ញឹម វណ្ណដា** ។

- ហេតុដូចនេះហើយទើបប្រជាពលរដ្ឋ និងមេភូមិមានការព្រួយបារម្ភដូចតទៅ :
  - ខ្លាចបាក់ទំនប់ធ្វើឱ្យខូចខាតទ្រព្យសម្បត្តិប្រជាពលរដ្ឋ ស្លាប់មនុស្ស និងខូចហេដ្ឋារចនាសម្ព័ន្ធ សាធារណៈ ។
  - បាក់ភ្នំ ឬរអិលភ្នំចុះមកក្រោម ធ្វើឱ្យខូចខាតទ្រព្យសម្បត្តិប្រជាពលរដ្ឋ ស្លាប់មនុស្ស និងខូចហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ។
- លោកមេភូមិ និងប្រជាពលរដ្ឋមិនជំទាស់នឹងរាជរដ្ឋាភិបាលដែលបានចុះហត្ថលេខាជាមួយក្រុមហ៊ុនវិនិយោគលើវិស័យអគ្គិសនីនេះទេ ។
- មេភូមិ និងប្រជាពលរដ្ឋក្នុងភូមិកំពង់គ្រែង មានសំណូមពរដល់រាជរដ្ឋាភិបាល និងក្រុមហ៊ុនដូចតទៅ :
  - សូមធ្វើយ៉ាងណាសិក្សាឱ្យបានច្បាស់លាស់រួចសាងសង់ទំនប់ឱ្យមាំ ដោយមានការជឿទុកចិត្តបាន កុំឱ្យបាក់ទំនប់ រំកិលបាក់ភ្នំ ។
  - ធ្វើយ៉ាងណាសូមឱ្យបើកមុខទឹកនៅថ្នល់រទេះភ្លើង និងផ្លូវជាតិលេខ ៣ ឱ្យធ្វើស្ពាន និងលូដាក់នៅលើផ្លូវទាំងនេះឱ្យគ្រប់គ្រាន់សំរាប់ដោះទឹកនៅរដូវវស្សា ។
  - សូមធ្វើការផ្គត់ផ្គង់ទឹកស្អាតដល់តំបន់គាត់ផង ។
  - សូមធ្វើការទូទាត់សងនៅពេលដែលគំរោងនេះធ្វើឱ្យគ្រោះថ្នាក់ និងខូចខាតដល់ប្រជាពលរដ្ឋក្នុងតំបន់ ។

បញ្ជីវត្តមានអ្នកភូមិកំពង់គ្រែងដែលបានចូលរួមប្រជុំពិគ្រោះយោបល់មានភ្ជាប់នៅឧបសម្ព័ន្ធ៤ ។

Draft

### ៦.៣.១៤ កំណត់ហេតុនៃការប្រជុំពិភាក្សា និងប្រឹក្សាយោបល់ខាងក្រុមការងារ ជាមួយតំណាងមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តកំពត

ការប្រជុំពិភាក្សា និងប្រឹក្សាយោបល់ជាមួយ លោក **ឈុន ហ៊ីម** ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល និងជាអនុគណៈកម្មការគំរោងវារីអគ្គិសនីកំចាយ ខេត្តកំពត បានធ្វើឡើងថ្ងៃទី ១៩/០៩/២០០៦ វេលាម៉ោង ០៤:០០ ដល់ ០៥:១៥ ល្ងាច មានដូចតទៅ :

- លោកបានដឹងអំពីគំរោងវារីអគ្គិសនីកំចាយ គឺតាមរយៈក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។
- លោកបានរាយការណ៍ថា មកដល់សព្វថ្ងៃនេះ (១៩/០៩/២០០៦) ក្រុមហ៊ុនចិនអនុវត្តសិក្សាលំអិតបានត្រឹមតែ ៤០% ប៉ុណ្ណោះ ។ នៅពេលសាងសង់គំរោងនឹងត្រូវការកម្មករចិនចំនួន ៤០០នាក់ កម្មករខ្មែរចំនួន ៨០០នាក់ ។ ចំពោះកន្លែងយកថ្មដើម្បីបំរើការសាងសង់វារីអគ្គិសនីនេះគឺ មានភ្នំ ២ ដែលអាចជ្រើសយកបាន គឺភ្នំវន្ទះបាញ់ និង

ភ្នំដូង ( យោងតាមការសិក្សារបស់ក្រុមការងារ SAWAC ភ្នំដូងគុណភាពថ្មអន់ មិនអាចយកមកលាយបេតុងធ្វើវារីអគ្គិសនីនេះបានទេ) ។

- លោកសំដែងការស្វាគមន៍ចំពោះគំរោងវារីអគ្គិសនីកំចាយ ហើយចំណាប់អារម្មណ៍ថា និងមានផលប្រយោជន៍ច្រើនដល់ប្រជាជនក្នុងតំបន់ និងប្រទេសជាតិ គឺមានថាមពលអគ្គិសនីប្រើប្រាស់ រួមចំណែកអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ទេសចរណ៍ និងកសិកម្មទៀតផង ។

### ៦.៣.១៥ កំណត់ហេតុនៃការប្រជុំពិភាក្សា និងប្រឹក្សាយោបល់ជាមួយក្រុមការងារ ជាមួយអ្នកលក់ដូរនៅតំបន់ទេសចរណ៍ទឹកឈូ

ការប្រជុំពិភាក្សា និងប្រឹក្សាយោបល់ជាមួយ ប្រជាពលរដ្ឋជាអ្នកលក់ដូរចំនួន ៥០នាក់ នៅក្នុងតំបន់រមណីយដ្ឋានធម្មជាតិទឹកឈូ ខេត្តកំពត បានធ្វើឡើងថ្ងៃទី ១៦/០៩/២០០៦ វេលាម៉ោង ០៨:៣០ ដល់ ០៩:៣០ ព្រឹក មានដូចតទៅ :

- ប្រជាពលរដ្ឋជាអ្នកលក់ដូរបានដឹងឮគំរោងនេះតាមរយៈឃើញក្រុមសិក្សាគំរោងរបស់ក្រុមហ៊ុនចិនមកខួងដីនៅតំបន់នេះ ក៏ប៉ុន្តែទើបនៅថ្ងៃទី ១៦/០៩/២០០៦ នេះបានដឹងច្បាស់ពីគោលបំណង និងទំហំការអភិវឌ្ឍន៍គំរោងតាមរយៈក្រុមសិក្សាហេតុប៉ះ ពាល់បរិស្ថាន និងសង្គមដំបូងនេះ ។
- អ្នកលក់ដូរទាំងនោះមានការព្រួយបារម្ភដូចតទៅ :
  - ខ្លាចបាក់ទំនប់ធ្វើឱ្យខូចខាតទ្រព្យសម្បត្តិប្រជាពលរដ្ឋ ស្លាប់មនុស្ស និងខូចហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ។
  - បាក់ភ្នំ ឬរអិលភ្នំចុះមកក្រោម ធ្វើឱ្យខូចខាតទ្រព្យសម្បត្តិប្រជាពលរដ្ឋ ស្លាប់មនុស្ស និងខូចហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ។
  - បាត់បង់មុខរបររបស់ប្រជាពលរដ្ឋដែលពឹងផ្អែកទៅលើការលក់ដូរបន្តិចបន្តួចនៅរមណីយដ្ឋានធម្មជាតិទឹកឈូនេះ ។
- ប្រជាពលរដ្ឋជាអ្នកលក់ដូរមិនជំទាស់នឹងរាជរដ្ឋាភិបាល ដែលបានចុះហត្ថលេខាជាមួយក្រុមហ៊ុនវិនិយោគលើវិស័យអគ្គិសនីនេះទេ ពីព្រោះ គំរោងនេះមានផលប្រយោជន៍ច្រើនដល់ប្រទេសជាតិ គឺមានអគ្គិសនី មានការអភិវឌ្ឍន៍លើវិស័យជាច្រើនទៀត ។
- ប្រជាពលរដ្ឋជាអ្នកលក់ដូរក្នុងតំបន់ទឹកឈូ មានសំណូមពរដល់រាជរដ្ឋាភិបាល និងក្រុមហ៊ុនដូចតទៅ :
  - សូមធ្វើយ៉ាងណាសិក្សាឱ្យបានច្បាស់លាស់រួចសាងសង់ទំនប់ឱ្យមាំ ដោយមានការជឿទុកចិត្តបាន កុំឱ្យបាក់ទំនប់ រំកិលបាក់ភ្នំ ។
  - សូមធ្វើផ្លូវវាងតំបន់រមណីយដ្ឋានទឹកឈូនេះ ដើម្បីទុកឱ្យពួកគាត់បន្តការលក់ដូរក្នុងតំបន់នេះតទៅទៀត ពីព្រោះពួកគាត់ពឹងផ្អែកតែលើអាជីពលក់ដូរនេះតែប៉ុណ្ណោះ ។

<u>សំគាល់</u>: ក្រុមការងារសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូងបានជូនដំណឹងលោកមេភូមិ ៣ថ្ងៃមុន ក៏ប៉ុន្តែ លោកមេភូមិបានបដិសេធ ហើយបាននាំកំលាំងនគរបាលអន្តរាគមន៍នៅតំបន់ទឹកឈូ ដឹកនាំដោយលោក **ឈន ឈឹម** មក ធ្វើការទាមទាររកលិខិតអនុញ្ញាតិឱ្យចុះមកសិក្សានេះទៀតផង ។



Draft

បញ្ជីវត្តមានអ្នកលក់ដូរនៅមេណីយដ្ឋានទឹកឈូដែលបានចូលរួមប្រជុំពិគ្រោះយោបមានភ្ជាប់នៅឧបសម្ព័ន្ធ៤ ។

## ៦.៤ ដំណោះស្រាយពីការប្រឹក្សាពិគ្រោះយោបល់ និងសំណូមពរពីសាធារណជន

បន្ទាប់ពីការធ្វើការប្រឹក្សាពិគ្រោះយោបល់ជាមួយសាធារណជន និងអ្នកដែលពាក់ព័ន្ធក្នុងគំរោងរួចមក ក្រុមការងារសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថានសង្គមដំបូង បានធ្វើការសម្របសម្រួល និងរកដំណោះស្រាយ ជាមួយក្រុមហ៊ុន ដែលផ្អែកលើកំណត់ហេតុខាងលើនេះ មានដូចតទៅ :

១- ក្រុមហ៊ុននឹងសិក្សារកផ្លូវវាងតំបន់រមណីយដ្ឋានទេសចរណ៍ធម្មជាតិទឹកឈូ ។

២- ក្រុមហ៊ុននឹងសិក្សាល់អិត នឹងសាងសង់ហេដ្ឋារចនាសម្ព័ន្ធទំនប់វារីអគ្គិសនីឱ្យរឹងមាំមិនឱ្យបាក់ ។

៣- ក្រុមហ៊ុននឹងសិក្សាតំបន់ភ្នំដែលនៅជុំវិញអាង ហើយរកវិធីសាស្ត្រសាងសង់ការពារភ្នំទាំងនោះមិនឱ្យរំកិលបាក់ទៅថ្ងៃអនាគត ។

៤- ក្រុមហ៊ុននឹងបើកទឹកមកខាងក្រោមទំនប់ទី ២ ដែលមានចារទឹកអប្បបរមាចំនួន ៦ម៣ /វិនាទី នារដូវប្រាំង ។

៥- ក្រុមហ៊ុននឹងថែទាំ និងជួសជុលផ្លូវលេខ ៣៨ ឱ្យល្អក្នុងពេលសាងសង់គំរោង ហើយពេលដែលគំរោងនេះសាងសង់ចប់ក្រុមហ៊ុននឹងអ៊ុតកៅស៊ូខ្ពង់ទំហំលើ ៧ម៉ែត្រទៀតផង ។

៦- ក្រុមហ៊ុននឹងទុកច្រកយកទឹកសំរាប់ប្រព័ន្ធស្រោចស្រពនៅអាងទី ២ ឱ្យមន្ទីរធនធានទឹក សំរាប់ប្រើប្រាស់ទៅថ្ងៃអនាគត ។

៧- ក្រុមហ៊ុននឹងទុកច្រកយកទឹកសំរាប់ប្រភពប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនៅអាងទី ២ អង្គភាពរដ្ឋាករទឹកខេត្តកំពត សំរាប់ប្រើប្រាស់ទៅថ្ងៃ អនាគត ។

៨- ចំពោះបញ្ហាប៉ះពាល់ដីធ្លីជាភារកិច្ចរបស់រាជរដ្ឋាភិបាល ក្រុមហ៊ុនគ្មានសិទ្ធិសំរេចបានទេ សូមឱ្យរាជរដ្ឋាភិបាលជួយដោះស្រាយផងចុះ ។

៩- ក្រុមហ៊ុននឹងផ្តល់អាទិភាពដល់ប្រជាជននៅក្នុងភូមិជុំវិញតំបន់គំរោង ក្នុងការជ្រើសរើសបុគ្គលិកកម្មករចូលបំរើការងាររបស់គំរោងនេះ ដោយធ្វើការពិភាក្សាជាមួយអ្នកតំណាងរបស់សហគមន៍ និងជាមួយប្រជាជនផ្ទាល់ ។

១០- ក្រុមហ៊ុនមានកម្មវិធីតាមដានត្រួតពិនិត្យលើការអនុវត្តន៍គំរោងច្បាស់លាស់ ដោយមានមន្ត្រីក្រុមចំរុះជាអ្នកអង្កេតតាមដាន ដូចមានចែងនៅក្នុងជំពូកទី ៧ : ផែនការគ្រប់គ្រងបរិស្ថាននៅក្នុងតំបន់គំរោងនេះស្រាប់ ។

Draft

# រូបថតប្រឹក្សាជាមួយស្ថាប័នពាក់ព័ន្ធ និង សាធារណជនដែលរស់នៅក្នុងតំបន់គំរោង

## ថ្ងៃទី ០៣ ដល់ ០៦/០៩/២០០៦



ប្រឹក្សាជាមួយលោក ស៊ី ហយ អភិបាលរងស្រុកកំពង់បាយ

ថ្ងៃទី ០៤/០៩/២០០៦



ប្រឹក្សាជាមួយលោក ចាន់ ចេស្តា ប្រធានមន្ទីរកសិកម្មខេត្ត

ថ្ងៃទី ០៤/០៩/២០០៦



ប្រឹក្សាជាមួយលោក ខ៊ែន ទិវៈ Project Director of CZM/DANIDA (NGO)

ថ្ងៃទី ០៤/០៩/២០០៦



ប្រឹក្សាជាមួយលោក ចាន់ វណ្ណា ប្រធានមន្ទីរធនធានទឹកខេត្ត

ថ្ងៃទី ០៥/០៩/២០០៦



ប្រឹក្សាជាមួយលោក យិន មុនី អនុប្រធានឧទ្យានជាតិបូកគោ

ថ្ងៃទី ០៥/០៩/២០០៦



ប្រឹក្សាជាមួយលោក ពត តាន់ណា អនុខ័ណ្ឌរដ្ឋបាលព្រៃឈើខេត្តកំពត

និង លោក សេង ឈេង នាយសង្កាត់រដ្ឋបាលព្រៃឈើ

ថ្ងៃទី ០៥/០៩/២០០៦

## <u>រូបថតប្រឹក្សាជាមួយស្ថាប័នពាក់ព័ន្ធ និង សាធារណជនដែលរស់នៅក្នុងតំបន់គំរោង</u>

## <u>ថ្ងៃទី ០៣ ដល់ ១៦/០៩/២០០៦</u>



ប្រឹក្សាជាមួយលោក សៅ សំបូរ អភិបាលរងស្រុកកំពត
និងលោក ស្វ ផន នាយខុទ្ទកាល័យស្រុកកំពត
ថ្ងៃទី ០៥/០៩/២០០៦



ប្រឹក្សាជាមួយលោក សាំង តេក មេភូមិមាត់ពាម
ថ្ងៃទី ០៦/០៩/២០០៦



ប្រឹក្សាជាមួយលោក ទង់ សាមុន អនុប្រធានរដ្ឋាករទឹកខេត្តកំពត
ថ្ងៃទី ០៧/០៩/២០០៦



ប្រឹក្សាជាមួយលោក សយ ស៊ីណុល អនុប្រធានមន្ទីរទេសចរណ៍ខេត្ត
ថ្ងៃទី ០៨/០៩/២០០៦





ប្រឹក្សាជាមួយលោក មិម ឈីជា មេភូមិព្រៃត្នោត ខេត្តកំពត
និង លោក ជូច ជឿន ក្រុមប្រឹក្សាអភិវឌ្ឍន៍ឃុំ និងប្រជាពលរដ្ឋភូមិព្រៃត្នោត
ថ្ងៃទី ១៤/០៩/២០០៦

Draft

# រូបថតប្រឹក្សាជាមួយស្ថាប័នពាក់ព័ន្ធ និង សាធារណជនដែលរស់នៅក្នុងតំបន់គំរោង

## ថ្ងៃទី ០៣ ដល់ ១៦/០៩/២០០៦



ប្រឹក្សាជាមួយលោក ភួប សារឿន មេភូមិ និងប្រជាពលរដ្ឋភូមិម៉ាក់ប្រាង្គ

ថ្ងៃទី ១៥/០៩/២០០៦



ប្រឹក្សាជាមួយលោក អ៊ុច ខនន មេភូមិ និងប្រជាពលរដ្ឋភូមិកំពង់គ្រែង

ថ្ងៃទី ១៥/០៩/២០០៦



ប្រឹក្សាជាមួយលោក ឈុន ហ៊ីម ប្រធានមន្ទីរឧស្សាហកម្មខេត្ត

និងជាអនុប្រធានគណៈកម្មការគំរោងវារីអគ្គិសនីកំចាយ

ថ្ងៃទី ១៥/០៩/២០០៦



ប្រឹក្សាជាមួយប្រជាពលរដ្ឋអ្នកលក់ដូរនៅរមណីយដ្ឋានទេសចរណ៍

ធម្មជាតិទឹកឈូ ខេត្តកំពត

ថ្ងៃទី ១៦/០៩/២០០៦

Draft